# លោក ខៀវ កាញារីទ្ធ: ទទួលបានអាសនៈ ៩០ គឺជាបន្ទុកយ៉ាងធ្ងន់ធ្ងរសំរាប់គណបក្សប្រជាជន

ដោយ ដួង សុខា



*ភ្នំពេញ ថ្ងៃទី ២៧ កញ្ញា ២០០៣(រូបឯកសារ) អ្នកនាំពាក្យរបស់គណបក្សប្រជាជនកម្ពុជា លោកខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានតាំងពីឆ្នាំ ២០០៤ ។*
*© ចន វីង / Magnum*

លោកខៀវ កាញារីទ្ធ អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជា និងជារដ្ឋមន្ត្រីក្រសួងព័ត៌មានផងដែរនោះ ត្រូវបានជាប់ឆ្នោតឡើងវិញជាតំណាងរាស្ត្រប្រចាំមណ្ឌលកំពង់ចាម ។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយវិបសាយព័ត៌មាន «កាសែត» កាលពីថ្ងៃសុក្រ ទី០១ សីហា ២០០៨ លោកខៀវ កាញារីទ្ធ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ដែលទទួលជ័យជំនះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រកាលពីថ្ងៃទី២៧ កក្កដាកន្លងមកនេះ បានអបអរសាទរចំពោះយុទ្ធសាស្ត្រនយោបាយរបស់គណបក្សខ្លួន ដែលចាប់ពីពេលនេះទៅជាគណបក្សនយោបាយនាំមុខគេនៅក្នុង ប្រទេស។ លោកបានពន្យល់ពីជោគជ័យដ៏ច្រើនលើសលប់របស់គណបក្សប្រជាជនកម្ពុជា និងឆ្លើយតបទៅការចោទពីភាពមិនប្រក្រតីនៅក្នុងការបោះឆ្នោតដែលបានបរិហារដោយគណបក្សប្រឆាំង និងអង្គការក្រៅរដ្ឋាភិបាលឃ្លាំមើលការបោះឆ្នោតនានា។ លោកក៏បានផ្តល់ការយល់ឃើញចំពោះគណបក្សនយោបាយផ្សេងនិងចាត់ទុក បក្សប្រឆាំងស្ថិតក្នុងលំដាប់ទី១ក្នុងការទប់រដ្ឋាភិបាល។

*សំណួរ៖ តើមូលហេតុអ្វីបានជាគណបក្សប្រជាជនអាចឈានទទួលជោគជ័យដ៏លើសលុបក្នុងការបោះឆ្នោតនេះ?*

**លោក ខៀវ កាញារីទ្ធ៖** គឺផ្អែកលើស្នូលពីរជាយុទ្ធសាស្ត្ររបស់យើង។ ទី១ ផ្អែកលើចំនួនរបស់សមាជិកបក្ស។ យើងឃើញថា ក្នុងចំណោមចំនួនប្រជាជន៨លាននាក់ដែលចុះឈ្មោះបោះឆ្នោត មានជាង៦០%ជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា។ ទី២ យើងផ្អែកលើអំពើល្អរបស់មន្ត្រីបក្ស។ យើងតែងតែទុកពេល ១ភាគ៦ អោយមន្ត្រីបក្សយើងម្នាក់ៗទៅធ្វើការជាប់ជាមួយប្រជាជន។ អំពើល្អគឺជៀសវាងអ្វីដែលប៉ះពាល់ប្រជាជន និយាយរួមគឺដោះស្រាយការងារអ្វីដែលពួកគាត់ចង់បាន ដូចជាធ្វើទំនប់ ធ្វើប្រឡាយ ធ្វើផ្លូវ សួរសុខទុក្ខ ឬក៏ជួយគាត់ពេលឆេះផ្ទះ...។

*សំណួរ៖ តើធ្វើដូចម្តេចបានជាមានអ្នកចូលគណបក្សប្រជាជនកម្ពុជាបានរហូតដល់ជាង៦០%?*

**លោក ខៀវ កាញារីទ្ធ៖** យើងពន្យល់គាត់អោយចូលគណបក្សប្រជាជនកម្ពុជា គាត់ព្រម។ កន្លែងខ្លះព្រមត្រឹមតែ៥០% មិនបាន១០០%ទេ។ ខ្លះកាន់បក្សនេះ ខ្លះកាន់បក្សនេះ យើងមិនអាចបង្ខំគាត់បានទេ។

*សំណួរ ៖ តើអ្វីទៅជាទិសដៅសំខាន់របស់គណបក្សប្រជាជនកម្ពុជាបន្ទាប់ពីការឈ្នះឆ្នោត?*

**លោក ខៀវ កាញារីទ្ធ៖** ទិសដៅសំខាន់គឺយើងបន្តយុទ្ធសាស្ត្រចតុកោណដំហានទី២។ ស្នូលគឺនៅតែជាអភិបាលកិច្ចល្អ ប៉ុន្តែសំខាន់គឺការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ការដោះស្រាយបញ្ហាផ្សេងៗ បង្កើនចំណេះដឹងដល់ប្រជាជន។ អញ្ចឹងហើយបានសូម្បីតែយើងឃោសនា ក៏យើងមិនភ្លេចជម្រាបប្រជាជនកុំអោយភ្លេចយកកូនទៅរៀន ព្រោះស្រុកឥឡូវនេះ ការប្រកួតប្រជែងគ្នាគឺដោយការប្រើខួរក្បាល។ ដើម្បីអាចប្រជែងចូលក្នុងទីផ្សារអន្តរជាតិបាន យើងត្រូវបង្កើនចំណេះដឹង។

*សំណួរ៖ តើការទទួលបានជោគជ័យរបស់គណបក្សប្រជាជនលើកនេះអាចមកពីកម្មវិធីនយោបាយរបស់ខ្លួនដែរឬទេ?*

**លោក ខៀវ កាញារីទ្ធ៖** កម្មវិធីនយោបាយផង ប៉ុន្តែយើងក៏ថាមកពីភាពចាស់ទុំផ្នែកនយោបាយរបស់ប្រជាជនយើងផងដែរ ពីព្រោះយើងឃើញហើយថា គណបក្សមួយចំនួនដែលជេរច្រើន មិនជាប់ឆ្នោតទេ ព្រោះពួកគាត់ដឹងហើយថា បើគេធ្វើជានាយករដ្ឋមន្ត្រីឬឈ្នះឆ្នោត ហើយថាពួកនេះគ្នាគេ ពួកនេះពួកអញ គឺមិនអាចបង្រួបបង្រួមជាតិបានទេ។ គណបក្សប្រជាជនមិនដែលជេរគណបក្សណាមួយទេ យើងដោះស្រាយទៅតាមគោលនយោបាយរបស់យើង។ ដូច្នេះឥឡូវនេះ ប្រជាជនគាត់យល់។ ចង់ដឹកនាំប្រទេសយ៉ាងម៉េច បើគាត់ជេរគេរហូត? បានន័យថាបើគាត់ឡើងកាន់អំណាចភ្លាម គាត់ប្រាកដជាបែងចែក គ្នាគាត់គ្នាគេភ្លាមៗ។ ឥឡូវប្រជាពលរដ្ឋមានការយល់ដឹងខ្ពស់។

**សំណួរ៖** *បន្ទាប់ពីបានជ័យជម្នះ តើថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជាសម្តែងអារម្មណ៍យ៉ាងដូចម្តេចដែរ?*

**លោក ខៀវ កាញារីទ្ធ៖** ជារួម គឺសប្បាយរីករាយផង និងជាបន្ទុកមួយផង។ ប្រជាជនទុកចិត្តបោះឆ្នោតអោយយើងដល់៩០កៅអីមិនមែនជារឿងលេងសើចទេ។ វាជាបន្ទុកមួយធ្ងន់ណាស់។ បន្ទុកនេះ យើងត្រូវរក្សានូវសណ្តាប់ធ្នាប់សង្គម សាមគ្គីភាពប្រជាជាតិ។ ដូចខ្ញុំបាននិយាយប្រាប់កាសែតដឹ ខាំបូឌា ឌែលី អញ្ជឹងថាត្បិតហ្វ៊ុនស៊ិនប៉ិចទទួលបានតែពីរកៅអី ប៉ុន្តែពេលគាត់ចូលជាមួយយើង មិនមែនថាអោយគាត់តែពីរកៅអីទេ យើងគិតដល់អ្នកផ្សេងទៀត។ រីឯគណបក្សផ្សេងទៀត ក៏យើងទទួលអោយចូលជាមួយដែរ។

**សំណួរ៖** *តើការទទួលជោគជ័យនេះអាចថាមកពីយើងបានចំណាយថវិកាច្រើនដែរឬទេ?*

**លោក ខៀវ កាញារីទ្ធ៖** និយាយរួម វាអាចច្រើនដែរ ប៉ុន្តែវាមិនមែនជាលុយរបស់គណបក្សប្រជាជនទាំងមូលទេ។ កន្លែងណាដែលគ្មានលទ្ធភាពសោះ ទើបគណបក្សផ្តល់ពីលើទៅ។ ក្រៅពីនេះ គឺបេក្ខជនម្នាក់ៗគាត់ប្រមែប្រមូលធនធានរបស់គាត់ដើម្បីចំណាយ។ ប៉ុន្តែ វាមិនច្រើនហួសពេកទេព្រោះថា គណបក្សខ្លះដល់ពេលឃោសនាទើបចំណាយលុយ។ ចំណែកយើង យើងធ្វើរាល់ថ្ងៃ រាល់ខែ ។ គ្រាន់តែចប់បោះឆ្នោតភ្លាម ឧទាហរណ៍ដូចអាទិត្យក្រោយនេះ យើងចាប់ផ្តើមប្រជុំដើម្បីរកមូលហេតុថា ហេតុអីកន្លែងនេះយើងចាញ់ កន្លែងនេះយើងឈ្នះ។ យើងចាប់ផ្តើមវិភាគមើលដកស្រង់បទពិសោធន៍ពីថ្នាក់ឃុំ បន្ទាប់មកថ្នាក់ខេត្ត រួចមកថ្នាក់កណ្តាលទៀត។ យើងដកពិសោធន៍ដើម្បីរៀនទាំងអស់គ្នា និងថាតើត្រូវធ្វើយ៉ាងម៉េចទៀត។ និយាយរួម យើងធ្វើការ៣៦៥ថ្ងៃ ហើយធ្វើការឃោសនាតែមួយខែ។

**សំណួរ៖** *ទាក់ទងនឹងចំនួនអាសនៈនេះ តើគណបក្សប្រជាជនមានបានរំពឹងទុកប៉ុន្មានមុនពេលបោះឆ្នោត?*

**លោក ខៀវ កាញារីទ្ធ៖** យើងរំពឹងថាបាន៨៩អាសនៈ។ ប៉ុន្តែយើងបានពីរបន្ថែមទៀត ពីព្រោះថាកន្លែងដែលយើងគិតថាមិនឈ្នះបានច្រើន តែបែរជាឈ្នះច្រើន។ **ទី១** គឺក្រុងភ្នំពេញយើងបានរហូតដល់៣កៅអីថែមទៀត (ពីមុន៤ ឥឡូវ៧កៅអី)។ **ទី២** គឺខេត្តកំពង់ចាម យើងបាន៣កៅអីថែមទៀត (ពីមុន៨កៅអី ឥឡូវ ១១កៅអី)។ កន្លងមក យើងគិតថាយកបានតែ១កៅអីៗថែមទៀតប៉ុណ្ណោះ។

**សំណួរ៖** *តើគណបក្សប្រជាជនកម្ពុជាយល់ឃើញយ៉ាងម៉េចដែរចំពោះភាពមិនប្រក្រតីនានាដែលលើកឡើងដោយគណបក្សមួយចំនួន? ការចេញទំរង់១០១៨ ការបាត់ឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ការបោះឆ្នោតលើឈ្មោះអ្នកដទៃជាដើម ។*

**លោក ខៀវ កាញារីទ្ធ៖** ខ្ញុំបានឆែកមើលហើយ យើងឃើញថា នៅមុនពេលដែលគេបិទបញ្ជីឈ្មោះបោះឆ្នោត និងពេលប្រកាសលទ្ធផលបណ្តោះអាសន្នជំហានដំបូង តំណាងគណបក្សទាំងអស់សុទ្ធតែបានចុះហត្ថលេខាថាត្រឹមត្រូវហើយ។

អ្នកថាគឺមេលើ តែតំណាងរបស់ខ្លួននៅតាមការិយាល័យសុទ្ធតែបានចុះហត្ថលេខា។ នេះគ្រាន់តែជាការបិទបាំងការចាញ់របស់ខ្លួនឯងទេ។ បើនិយាយពីនីតិវិធីត្រូវមើលឡើងវិញ យើងអនុញ្ញាតអោយមានអ្នកសង្កេតការណ៍របស់គណបក្សនីមួយៗផង និងអ្នកសង្កេតការណ៍ផ្សេងៗផង។ ពួកគេសុទ្ធតែបានចុះហត្ថលេខាទទួលស្គាល់លទ្ធផលបោះឆ្នោតនេះថាត្រឹមត្រូវ។ មានតិចតួចណាស់ដែលជំទាស់។ អញ្ចឹងមិនអាចមេបក្សនៅខាងលើមកនិយាយលេងបានទេ គឺវាផ្អែកលើហត្ថលេខារបស់តំណាងរបស់ខ្លួនឯណោះ។

**សំណួរ៖** *តើឯកឧត្តមគិតថាមានគម្លាតខុសគ្នាឆ្ងាយទេរវាងអាសនៈដែលគណបក្សប្រជាជនទទួលបានជាមួយនឹងគណបក្សផ្សេងទៀត?*

**លោក ខៀវ កាញារីទ្ធ៖** នេះមកពីគណបក្សខ្លះ មួយឆ្នាំ មិនដែលឃើញគាត់ចុះទៅមូលដ្ឋានម្តងផង។ ប្រជាជនចេះគិត ហើយនេះបង្ហាញពីភាពចាស់ទុំរបស់ប្រជាជន។ ពួកគាត់មើលណាស់ គាត់មិនមែនមើលមេបក្សនោះពូកែនិយាយ គាត់មើលទៀតថាតើនរណាធ្វើជាបេក្ខជននៅកន្លែងគាត់រស់នៅ។

**សំណួរ៖** *ទាក់ទងនឹងលទ្ធផល គណបក្សប្រជាជនកម្ពុជាទទួលបាន៩០អាសនៈ។ តើទៅថ្ងៃអនាគតអាចថាគណបក្សប្រជាជននឹងធ្វើអ្វីតាមតែខ្លួនចង់រឺទេ។ មានអ្នកខ្លះព្រួយបារម្ភថា គណបក្សប្រជាជននឹងសម្រេចអ្វីដោយខ្លួនឯងដោយគ្មានសំឡេងពីគណបក្សប្រឆាំង។ តើឯកឧត្តមមានយោបល់យ៉ាងណាដែរចំពោះចំណុចនេះ?*

**លោក ខៀវ កាញារីទ្ធ៖** អញ្ចឹងបានយើងទុកគណបក្សសម រង្ស៊ី នៅជាគណបក្សប្រឆាំងតទៅទៀត ព្រោះគាត់មានកៅអីច្រើន អោយគាត់នៅជាបក្សប្រឆាំងតទៅទៀត។ ធម្មតា នៅក្នុងរបបប្រជាធិបតេយ្យ ត្រូវមានបក្សប្រឆាំងមួយខ្លាំងក្លា។ ដូច្នេះ គាត់បាន២៦កៅអី ហើយបើបូកជាមួយ កឹម សុខា (ប្រធានគណបក្សសិទ្ធិ មនុស្ស) ចង់ប្រឆាំងទៀត ឡើង២៨ , ជាមួយព្រះអង្គម្ចាស់រណឫទ្ធិ (ប្រធានគណបក្សនរោត្តម រណឫទ្ធិ) ពីរទៀតបាន៣០ គឺសរុបទៅបាន១ភាគ៣នៃគណបក្សប្រជាជនដែរ។

នៅក្នុងរបបប្រជាធិបតេយ្យ ពិតមែនតែយើងឈ្នះ៩០កៅអី ឬក៏យើងបានដល់១០០ក្តី បើយើងប្រហែសយើងអាចបាត់សន្លឹកឆ្នោតវិញ។ នេះជាការសំខាន់ណាស់ដែលរក្សាជំហរគោលនយោបាយដែលយើងបានប្រកាសជាមួយប្រជាពលរដ្ឋ។ ដូចខ្ញុំបាននិយាយអម្បាល់មិញ គឺអំពើល្អរបស់មន្ត្រីបក្សដែលជាកត្តាកំណត់អោយយើងឈ្នះ។ បើយើងគិតថា អាណត្តិក្រោយជិះសេះលែងដៃនោះយើងនឹងធ្លាក់ក្តុក។ ប្រជាជនគាត់តាមមើលគាត់ទុកចិត្ត គាត់បោះអោយ។ គាត់ចាំមើលថា តើអ្នកឯងធ្វើអ្វីខ្លះតាមកិច្ចសន្យាបាន ឬមិនបាន។ ដូច្នេះ គណបក្សប្រជាជនត្រូវបន្ថឹងជាមួយមន្ត្រីរបស់ខ្លួនថែមទៀត ដើម្បីអោយខិតខំ និងសក្តិសមដែលប្រជាជនគាត់ទុកចិត្តបោះឆ្នោតអោយ។

**សំណួរ៖** *ពិតមែនតែគណបក្សប្រជាជនទទួលបានអាសនៈច្រើន តែរាល់ការធ្វើច្បាប់អ្វីផ្សេងៗ យើងនៅតែត្រូវការអនុសាសន៍ពីគណបក្សផ្សេង និងពីសង្គមស៊ីវិលទៀតឬយ៉ាងណា?*

**លោក ខៀវ កាញារីទ្ធ៖** ធម្មតាត្រូវតែមាន។ កន្លងមក ដូចធ្វើវារីអគ្គិសនី យើងធ្វើសិក្ខាសាលាពីរបីដង យើងអញ្ជើញសង្គមស៊ីវិលអោយចូលរួម។ ដូចធ្វើច្បាប់រៀបចំក្រុង សង្កាត់ក៏ដូចគ្នាដែរ យើងបើកជាសិក្ខាសាលាថ្នាក់ជាតិ តែសង្គមស៊ីវិលមិនសូវចូលរួមទេ។ តែច្បាប់ប្រឆាំងអំពើពុករលួយ មានការចូលរួមច្រើនបំផុតពីសង្គមស៊ីវិល ព្រោះវាមានជំនួយច្រើន។

ដូចច្បាប់ស្ដីពីការរៀបចំខេត្ត ក្រុង គាត់បញ្ជូនមនុស្សកំប៉ិកកំប៉ុកទៅស្ដាប់ ហើយជួនកាលស្ដាប់មិនដឹងអីផង ដូច្នេះយើងសូមស្នើអោយខាងសង្គមស៊ីវិលមានភាពសកម្មបន្តិច។ សង្គមស៊ីវិលនៅតែជាដៃគូខានមិនបានរបស់រដ្ឋាភិបាល។

**សំណួរ៖** *ក្នុងនាមគណបក្សកាន់អំណាច តើឯកឧត្ដមយល់ឃើញយ៉ាងណាដែរពីអនាគតគណបក្សប្រឆាំង?*

**លោក ខៀវ កាញារីទ្ធ៖** ទី១ យើងគិតថាមិនមែនបង្ខំអោយគ្រប់គ្នាត្រូវតែពេញចិត្តបក្សប្រជាជនមួយទេ ។ ការមានគណបក្សច្រើនឬតិចមិនមែនមានន័យថាជាការទន់ខ្សោយប្រជាធិបតេយ្យទេ។ សហរដ្ឋអាមេរិកមានបក្សតែពីរទេ ប៉ុន្តែបញ្ហាធំគឺមិនអោយមានគណបក្សច្រើនទេ ព្រោះមានបក្សច្រើន សង្គមមិនរឹងមាំ ។

បក្សប្រឆាំងត្រូវតែមាន បើមិនអីចឹងទេមន្ត្រីរដ្ឋាភិបាលជិះសេះលែងដៃមិនខាន។ បក្សប្រឆាំងមួយ សង្គមស៊ីវិលពីរ និងសេរីភាពសារព័ត៌មានបី គឺសំខាន់ណាស់សម្រាប់ទប់កុំអោយរដ្ឋាភិបាលជិះសេះលែងដៃ។

យើងមិនមានការព្រួយបារម្ភចំពោះការរួមគ្នារបស់បក្សប្រឆាំងទេ ព្រោះគណបក្សប្រជាជនកម្ពុជាមិនមានការធ្លាក់អ្នកបោះឆ្នោតទេ។

**សំណួរ៖** *ចំពោះការបង្កើតរដ្ឋាភិបាល តើគោលជំហររបស់គណបក្សប្រជាជននៅតែសហប្រតិបត្តិការជាមួយគណបក្សហ្វ៊ុនស៊ិនប៉ិចទៀតឬយ៉ាងណា?*

**លោក ខៀវ កាញារីទ្ធ៖** និយាយត្រង់ទៅ ទី១ហ្វ៊ុនស៊ិនប៉ិចធ្វើការជាមួយយើងបីអាណត្តិមកហើយ។ ទី២ គឺមន្ត្រីរបស់បក្សនេះសុទ្ធតែមានបទពិសោធន៍ការងារ។ ចំណែកឯគណបក្សខ្លះវិញ សមាជិកមិនដែលចូលធ្វើការផងទេ គាត់មិនដែលយល់ការងារសោះ។

អ្វីដែលសំខាន់សំរាប់យើង គឺយើងទើបបញ្ចប់ច្បាំងគ្នា ដូច្នេះសាមគ្គីភាពប្រជាជាតិយើងជាការងារធំ។

**សំណួរ៖** *គណបក្សប្រជាជនកម្ពុជាធ្លាប់ប្រកាសថាសហការជាមួយតែគណបក្សហ្វ៊ុនស៊ិនប៉ិចដែលដឹកនាំដោយលោកញឹក ប៊ុនឆៃ (អគ្គលេខាធិការហ្វ៊ុនស៊ិនប៉ិច) ។ តើគណបក្សប្រជាជនដូរជំហរនេះ ឬនៅរក្សាជំហរនេះដដែល?*

**លោក ខៀវ កាញារីទ្ធ៖** ចំពោះបញ្ហានេះ នៅពេលមានការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) គណបក្សប្រជាជនកម្ពុជានឹងធ្វើការប្រជុំដើម្បីធ្វើការសម្រេចជាផ្លូវការ។ ឥឡូវលោកកែវ ពុទ្ធរស្មី មានប្រសាសន៍ថា គាត់អត់មានប្រឆាំងអីទេចំពោះលទ្ធផលបោះឆ្នោត។ យើងមិនចង់អោយហ៊្វុនស៊ិនប៉ិចបែកបាក់គ្នាទេ។ សំខាន់យើងចង់អោយគាត់ត្រូវគ្នាជាក្រុមមួយដើម្បីពិចារណា។ ហ៊្វុនស៊ិនប៉ិចចាញ់កាលពីលើកមុនពីជាង៤០កៅអីមកនៅជាង២០កៅអីនេះ គឺដោយសារគាត់ដេរគណបក្សប្រជាជន។ គាត់ដេររដ្ឋាភិបាលក្នុងពេលដែលគាត់នៅក្នុងរដ្ឋាភិបាលដែរ។ ឧទាហរណ៍ថា គាត់ជិះទូក គាត់ដេរអ្នកអុំទូក។ ដូច្នេះ យើងចង់អោយគាត់រៀនពិចារណារកយុទ្ធសាស្រ្តមួយត្រឹមត្រូវ។ គណបក្សប្រជាជនកម្ពុជាមានក្រុមមួយអង្គុយគិត គឺគេមិនចេញមុខទេ តែសម្រាប់វិភាគពិចារណា។

ឥឡូវនេះ និយាយរួម គឺយើងជាដៃគូហ៊្វុនស៊ិនប៉ិចហើយ ប៉ុន្តែយើងនឹងសម្រេចរើសអ្នកណាទៀត។ ឯកឧត្តមញឹក ប៊ុនឆៃ ត្រូវធ្វើបញ្ជីមក ដាក់នរណាខ្លះ គាត់សុំចង់បានឋានៈនោះ រួចយើងពិចារណាទៅ ហើយយើងជជែកគ្នា។ នេះជាការងាររបស់គាត់ យើងមិនលូកដៃចូលទេ។

**សំណួរ៖** *ហេតុអ្វីបានជាគណបក្សប្រជាជនកម្ពុជាមិនរើសលោក កែវ ពុទ្ធរស្មី ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច?*

**លោក ខៀវ កាញារីទ្ធ៖** កន្លងមក លោកកែវ ពុទ្ធរស្មី បានធ្វើខុស។ ទី១ អ្នកអង្គម្ចាស់សិរីវ័ឌ្ឍ (អនុប្រធានទី២គណបក្សហ៊្វុនស៊ិនប៉ិច) បានចុះហត្ថលេខាជាមួយគណបក្សផ្សេង ប្រឆាំងនឹងលទ្ធផលបោះឆ្នោត។ ទី២ ពួកយើងមានកិច្ចព្រមព្រៀងគ្នា បើយើងសម្រេចអី យើងត្រូវជូនដំណឹងគ្នាជាមុន តែគាត់មិនបានប្រាប់យើងទេ។ គាត់បានសរសេរលិខិតសុំដកពាក្យបណ្តឹងលើសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដោយមិនបានប្រាប់យើងជាគណបក្សដៃគូ។ រឿងនេះមិនត្រឹមត្រូវទេ។

**សំណួរ៖** *បន្ទាប់ពីគណបក្សប្រជាជនបានជោគជ័យ តើឯកឧត្តមគិតថាទៅមុខទៀត ប្រទេសជាតិនឹងមានការប្រែប្រួលដែរឬទេ ដូចជាបញ្ហានយោបាយ និងសេដ្ឋកិច្ចជាដើម?*

**លោក ខៀវ កាញារីទ្ធ៖** និយាយរួម យើងឃើញមានវិនិយោគិនបរទេសចូលមកច្រើន គឺដោយសារគណបក្សប្រជាជន ជាបក្សមួយមានបទពិសោធន៍ជាច្រើនក្នុងការដឹកនាំ ហើយជាគណបក្សដែលមានសមត្ថភាព។ យើងគិតថា ការវិនិយោគនឹងកាន់តែចូលមកខ្លាំងថែមទៀត។ ទន្ទឹមនឹងសេដ្ឋកិច្ច យើងនៅមានកំណើនដោយសារថាពិតមែនតែប្រេងថ្លៃ តែសូម្បីវិនិយោគិនបរទេសក៏ទទួលស្គាល់ដែរថា នៅកម្ពុជា កំណើនសេដ្ឋកិច្ចឡើងខ្លាំង វាធ្វើអោយយើងទប់បានការរអ៊ូរទាំនឹងការឡើងថ្លៃនេះ។ ចាប់ពីឆ្នាំ២០១២ យើងនឹងមានអគ្គិសនី ហើយរដ្ឋាភិបាលធានាថា ៣០ឆ្នាំនឹងមិនមានការឡើងថ្លៃ(អគ្គីសនី)ទេ។ យើងរកប្រេង ឧស្ម័នបាន ហើយផ្តល់ការងារដល់បងប្អូនខ្មែរយើង។ ដូចយើងឃើញសព្វថ្ងៃ វិស័យកាត់ដេរយើងខ្វះមនុស្សធ្វើការជាង២ម៉ឺននាក់។

រោងចក្រមួយៗ ត្រូវការមនុស្ស១ពាន់ ទៅ ពីរពាន់នាក់។ អ្វីដែលសំខាន់ទៅទៀត ក្នុងរោងចក្រកាត់ដេរ យើងមិនត្រឹមត្រូវការតែកម្មករទេ យើងត្រូវការមេការ (អ្នកធ្វើការថ្នាក់កណ្ដាល) ពីព្រោះច្បាប់ការងាររបស់យើងអ្នកណាមកធ្វើរោងចក្រនៅស្រុកខ្មែរ គឺត្រូវតែប្រើពលករខ្មែរ លើកលែងតែយើងអត់មានមនុស្ស តែសព្វថ្ងៃបញ្ហាធំគឺយើងអត់ទាន់មានមេការ។ កាលណាយើងមានមេការខ្មែរច្រើន យើងអាចជៀសវាងការប៉ះទង្គិចក្នុងការងារ។

ក្នុងវិស័យសំណង់ក៏ខ្វះច្រើនដែរ យើងត្រូវការ៧០០០នាក់ទៅ៨០០០នាក់។ វាមានការងារច្រើនណាស់ដែលយើងត្រូវធ្វើ ហើយពីរឆ្នាំទៀត យើងត្រូវការជាងអគ្គិសនី.... ដូច្នេះបានជាធ្វើអោយបក្សខ្លះបារម្ភ ព្រោះថាតែកាលណាគេចាញ់ហើយ មិនងាយនឹងស្តារឡើងវិញទេ លុះត្រាតែគណបក្សឈ្នះភ្លេចខ្លួន។

រីឯទិដ្ឋភាពនយោបាយវិញ គឺមិនអីទេ។ បញ្ហាធំគឺយើងបន្តសម្ព័ន្ធភាពជាមិត្តនៅក្នុងអាស៊ាន។ ទី២ បញ្ចូលខ្លួនទៅក្នុងសហគមន៍អន្តរជាតិ (ទីផ្សារអន្តរជាតិ)។

**សំណួរ៖** *មកទល់ពេលនេះ តើមានការបែងចែកតួនាទីអ្វីហើយឬនៅក្នុងគណបក្សប្រជាជនកម្ពុជា បន្ទាប់ពីការឈ្នះឆ្នោត?*

**លោក ខៀវ កាញារីទ្ធ៖** អត់ទេ។ មិនទាន់ទេ។ នៅក្នុងគណបក្សប្រជាជន ថ្នាក់ដឹកនាំមួយត្រូវត្រៀមអ្នកស្នងពីររូប។

**សំណួរ៖** *តើឯកឧត្តមនៅជារដ្ឋមន្ត្រីក្រសួងព័ត៌មានដដែលឬយ៉ាងម៉េច?*

**លោក ខៀវ កាញារីទ្ធ៖** អត់ដឹងទេ។ ប៉ុន្តែភាគច្រើន ខ្ញុំគិតថាប្រហែលនៅដដែលច្រើនគ្នា។ បញ្ហាតួនាទីនេះគឺខាងគណៈកម្មាធិការប្រតិបត្តិរបស់បក្សជាអ្នកសម្រេច។

**សំណួរ៖** *ក្នុងការរង់ចាំការប្រកាសលទ្ធផលបោះឆ្នោតផ្លូវការ តើមានកិច្ចការបន្ទាន់អ្វីដែលគណបក្សប្រជាជនកម្ពុជាត្រូវធ្វើ?*

**លោក ខៀវ កាញារីទ្ធ៖** សំខាន់គឺការរក្សាសណ្ដាប់ធ្នាប់សង្គម និងកិច្ចការព្រះវិហារ។

រក្សាសិទ្ធដោយក្រសួងព័ត៌មាន